អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៣

# សេចក្តីប្រកាសព័ត៌មាន

## អគ្គទេសាភិបាលនៃប្រទេសណូវ៉ែលហ្សេឡង់ ប្រកាសសន្យាផ្តល់ថវិកាបន្ថែម ក្នុងអំឡុងពេលធ្វើទស្សនកិច្ចនៅ អ.វ.ត.ក

ថ្ងៃនេះ ឯកឧត្តមឧត្តមសេនីយ៍ឯក Jerry Mateparae អគ្គទេសាភិបាលនៃប្រទេសណូវ៉ែលហ្សេឡង់ បានប្រកាសសន្យាផ្តល់ថវិកាបន្ថែមចំនួន ២០០.០០០ ដុល្លារណូវ៉ែលហ្សេឡង់ ជូនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ក្នុងអំឡុងពេលដែលឯកឧត្តមមកធ្វើទស្សនកិច្ចនៅ អ.វ.ត.ក ដើម្បីបង្ហាញនូវការគាំទ្ររបស់ប្រទេសឯកឧត្តមចំពោះតុលាការនេះ។ ថវិកាដែលបានសន្យានេះគឺផ្តល់ជូនទៅភាគីជាតិនៃ អ.វ.ត.ក។

ឯកឧត្តមអគ្គទេសាភិបាលបានដឹកនាំគណៈប្រតិភូចំនួន ១៤ រូបមកកាន់ អ.វ.ត.ក ក្នុងអំឡុងពេលឯកឧត្តម ធ្វើទស្សនកិច្ចផ្លូវរដ្ឋក្នុងប្រទេសកម្ពុជា។ នេះគឺជាលើកទីមួយហើយដែលមេដឹកនាំមួយរូបដែលមានឋានៈជាប្រមុខរដ្ឋបានមកទស្សនកិច្ចនៅ អ.វ.ត.ក។

ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលកម្ពុជាសម្រាប់តុលាការខ្មែរក្រហម និងឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទីនៃអ.វ.ត.ក បានស្វាគមន៍ឯកឧត្តមអគ្គទេសាភិបាល ព្រមទាំងបានជួបពិភាក្សាអំពីការវិវឌ្ឍថ្មីៗរបស់តុលាការ និងបញ្ហាប្រឈមផ្សេងៗ ដែលតុលាការបាននិងកំពុងជួបប្រទះដើម្បីបញ្ចប់អាណត្តិរបស់ខ្លួន។

នាកិច្ចប្រជុំនោះ ឯកឧត្តមអគ្គទេសាភិបាល មានប្រសាសន៍ថា៖ “យើងទទួលស្គាល់ថា ប្រជាជនកម្ពុជាពឹងផ្អែកលើសាលាក្តីនេះនៅក្នុងដំណើរការផ្សះផ្សាជាតិ ហើយប្រទេសណូវ៉ែលហ្សេឡង់ នឹងបន្តជួយសាលាក្តីនេះរហូតទាល់តែបញ្ចប់ភារកិច្ចរបស់ខ្លួនក្នុងការជំនុំជម្រះក្តីលើមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម”។ បន្ទាប់មក ឯកឧត្តមបានប្រកាសថា ប្រទេសណូវ៉ែលហ្សេឡង់បានសន្យាផ្តល់ថវិកាចំនួន ២០០.០០០ ដុល្លារណូវ៉ែលហ្សេឡង់ ទៅខាងភាគីជាតិនៃសាលាក្តីនេះ ដែលកំពុងប្រឈមនឹងបញ្ហាហិរញ្ញវត្ថុ និងដែលកំពុងស្វែងរកជំនួយជាចាំបាច់។

នៅក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន បានមានប្រសាសន៍ថា៖ “យើងខ្ញុំសូមថ្លែងអំណរគុណ ដោយបានដឹងថា ប្រទេសណូវ៉ែលហ្សេឡង់នឹងផ្តល់ថវិកាបន្ថែមជួយគាំទ្រ អ.វ.ត.ក ដើម្បីឲ្យសាលាក្តីនេះអាចបញ្ចប់សំណុំរឿងដែលមាននៅចំពោះមុខ។ ការប្រកាសផ្តល់ថវិកាបន្ថែមនេះ គឺធ្វើឡើងនៅក្នុងពេលដ៏សមស្របដែលអង្គជំនុំជម្រះសាលាដំបូងកំពុងត្រៀមរៀបចំធ្វើសវនាការស្តាប់សេចក្តីសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោល ក្នុងសំណុំរឿង០០២/០១ មុននឹងចេញសាលក្រមរបស់ខ្លួន។ ការសន្យាផ្តល់ថវិកានេះគឺជា សញ្ញាបញ្ជាក់អំពីការប្តេជ្ញាចិត្តជាថ្មីរបស់ប្រទេសម្ចាស់ជំនួយ ក្នុងការជួយគាំទ្រតុលាការនេះ ក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាទាំងមូល”។

ក្នុងអំឡុងពេលធ្វើទស្សនកិច្ចនេះដែរ ឯកឧត្តមអគ្គទេសាអភិបាល និងគណៈប្រតិភូរបស់លោក ក៏បានជួបសំណេះសំណាលជាមួយលោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង និងលោកស្រីចៅក្រម Silvia Cartwright ដែលជាចៅក្រម មកពីប្រទេសណូវ៉ែលហ្សេឡង់ ដើម្បីបានយល់ដឹងពិស្តារអំពីកិច្ចការតុលាការ និងបានធ្វើទស្សនាសាលសវនាការរបស់ អ.វ.ត.ក ផងដែរ។

ប្រទេសណូវ៉ែលហ្សេឡង់បានជួយគាំទ្រ អ.វ.ត.ក តាំងពីដើមដំបូងមកម្ល៉េះ ហើយកន្លងមក បានផ្តល់ថវិកាចំនួន ១,២ លានដុល្លារណូវ៉ែលហ្សេឡង់រួចមកហើយជូនដល់ អ.វ.ត.ក។ ការផ្តល់វិភាគទានចុងក្រោយ បានធ្វើឡើងកាលពីខែវិច្ឆិកាកន្លងទៅនេះ គឺនៅអំឡុងពេលដែលឯកឧត្តមនាយករដ្ឋមន្ត្រី John Key មកធ្វើទស្សនកិច្ចនៅសាលាក្តីនេះ។ គិតទាំងថវិកាដែលសន្យាថានឹងផ្តល់ជូននៅលើកនេះទៀត ថវិកាដែលប្រទេសណូវ៉ែលហ្សេឡង់ផ្តល់ជូន អ.វ.ត.ក នឹងមានចំនួនសរុប ១,៤ លានដុល្លារណូវ៉ែលហ្សេឡង់។

ចំពោះព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥(០)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh

**លោកស្រី យូកូ ម៉ៃដា**
មន្ត្រីផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទដៃ: +៨៥៥ (០)១២ ៤៨៨ ៣១៩
សារអេឡិកត្រូនិក: maeday@un.org